អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងធ្វើរ៉ាកែតវាយប៉េងប៉ុង**

**ចិត្តចលភាព**៖បំណិនចលនាតូច៖ការហ្វឹកហាត់បង្កើនកម្លាំងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក។

**សិក្សាសង្គម**៖ គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងពេញចិត្តចំពោះសិល្បៈតាមការបង្កើតរូបភាព៖

**បុរេគណិត**៖ រង្វាស់រង្វាល់៖ បញ្ញបត្តិស្តីពីរង្វាស់រង្វាល់៖ បញ្ញត្តិនៃរូបរាង និងលំហ។

**គោលបំណង** ៖

**ចិត្តចលភាព**៖ មានអំណត់ តស៊ូព្យាយាមនិងសប្បាយរីករាយក្នុងការធ្វើអ្វីមួយ ឬលេងល្បែងឱ្យបានរឹងមាំនិងជោគជ័យ។

**សិក្សាសង្គម**៖ ប្រាប់បានពីរបៀបនៃការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។ ធ្វើឱ្យក្មេងៗមានសកម្មភាព រហ័សរហួននិងប្រុងប្រយ័ត្នក្នុងការចាប់កាន់ បត់ សូន គូរ ហែកនិងផាត់ពណ៌ជាដើម…។

**បុរេគណិត** ៖ ប្រាប់បានពីរូបរាងសាមញ្ញពីធរណីមាត្រដូចជា៖ រូបរាងការេ ត្រីកោណ រង្វង់និងចតុកោណកែងជាដើម…។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសកេះ ឬក្រដាសអ្វីដែលមានសភាពរឹងល្មម កន្ត្រៃ ស្កុត។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**ការរៀបចំ** ៖ រៀបចំធ្វើរ៉ុកកែតមួយឈុតសម្រាប់បង្ហាញកុមារជាមុនសិន។

**សេចក្តីណែនាំ**៖

1. ប្រាប់កុមារថាថ្ងៃនេះ ពួកយើងនឹងលេងល្បែងមួយដែលមានឈ្មោះថាល្បែងធ្វើរ៉ុកកែតវាយប៉េងប៉ុង។
2. សួរកុមារថា តើកូនៗស្គាល់កីឡាវាយប៉េងប៉ុងដែរឬទេ? ធ្លាប់លេងកីឡាហ្នឹងដែរឬទេ?
3. កូនៗបានមើលការប្រកួតកីឡា នៅក្នុងព្រឹត្តិការណ៍ ស៊ីហ្គេមឆ្នាំ២០២៣ដែរឬទេ? តើនៅក្នុងស៊ីហ្គេមមានកីឡាវាយប៉េងប៉ុងដែរឬទេ?

4. បន្ទាប់មកបង្ហាញពីរុកកែតមួយឈុតដែលបានធ្វើនិងត្រៀមនោះ ទៅកាន់កុមារមុនពេលធ្វើវាទាំងអស់គ្នា។
   វិធីធ្វើ៖
   - ប្រើកន្ត្រៃកាត់ក្រដាសកេះជារាងរង្វង់ចំនួន២ (សម្រាប់មួយឈុត)
   - កាត់ក្រដាសកេះមួយផ្សេងទៀត បកយកស្រទាប់ខាងលើ (ឬប្រើក្រដាសកេះណាដែលមានសភាពទន់ ដើម្បីងាយស្រួលក្នុងការមូរវាជាទីប) សម្រាប់ធ្វើជាដងរបស់វា។ ត្រូវមូរវាជារាងទីប កុំស្តើងពេកនិងកុំក្រាស់ពេក គឺល្មមបានហើយ។
   - បន្ទាប់មកពុះវានៅចំកណ្តាលនិងដាក់វាគាបនៅចន្លោះក្រដាសកេះដែលយើងបានកាត់ជារង្វង់នោះ បន្ទាប់មកទៀត ប្រើស្កុតបិទវាទាំងសងខាងឱ្យមានសភាពរឹងមាំជាការស្រេច។
   - ធ្វើបែបនេះសម្រាប់រុកកែតទាំងអស់តែម្តង។
5. ពេលធ្វើរួចរាល់អាចឱ្យក្មេងៗលេងកីឡាវាយប៉េងប៉ុងនេះបាន ប្រសិនបើមានគ្រាប់របស់វា។
6. ពួកគេអាចប្រើប៉ោងប៉ោងធ្វើគ្រាប់ក្នុងការលេងល្បែងនេះក៏បានដែរ ដែលមានទំហំទៅតាមការរៀបចំរបស់អ្នក។